# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១៥២ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ នៃវិទ្យាស្ថានជាតិទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ នៃវិទ្យាស្ថានជាតិទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅជំរុញនិងលើកកម្ពស់ការងារសិក្សាស្រាវជ្រាវវិភាគផលប៉ះពាល់ និន្នាការទេសចរណ៍ថ្មីៗក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងតំបន់ ក៏ដូចជាសកលលោក ដើម្បីប្រមូលបានធាតុចូលសំខាន់ៗ និងចងក្រងគោលនយោបាយទេសចរណ៍សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ឱ្យកាន់តែរីកចម្រើន និងមាននិរន្តរភាព។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍** ចំណុះវិទ្យាស្ថានជាតិទេសចរណ៍ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ទទួលបន្ទុកការងារសិក្សាស្រាវជ្រាវ គោលនយោបាយ យុទ្ធសាស្ត្រ វិភាគផលប៉ះពាល់ និងនិន្នាការទេសចរណ៍ តាមដានព្រឹត្តិការណ៍ទេសចរណ៍ក្នុងស្រុក តំបន់ និងសកលលោក ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំគោលនយោបាយទេសចរណ៍កម្ពុជា ដោយធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ អន្តរជាតិ។

**នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ វិភាគពីវិស័យទេសចរណ៍ និងវិស័យពាក់ព័ន្ធ ក្នុងសមត្ថកិច្ចពិគ្រោះយោបល់របស់ក្រសួងទេសចរណ៍ ដូចមានចែងក្នុងច្បាប់ទេសចរណ៍
- សិក្សាស្រាវជ្រាវ និងវិភាគអំពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទេសចរណ៍ ស្ថានភាពទេសចរណ៍ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់តំបន់ទេសចរណ៍ដែលមានសក្តានុពល ដើម្បីអភិវឌ្ឍឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- ព្យាករណ៍តម្រូវការហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ដទៃទៀតដែលបម្រើឱ្យវិស័យទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគពីផលប្រយោជន៍វិស័យទេសចរណ៍ ផលប៉ះពាល់វិជ្ជមាន អវិជ្ជមាននៃវិស័យនេះមកលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- សិក្សាស្រាវជ្រាវ វិភាគអំពីការទទួលរងនូវផលប៉ះពាល់ពីវិស័យដទៃមកលើវិស័យទេសចរណ៍
- សហការជាមួយអង្គការទេសចរណ៍ជាតិ អន្តរជាតិ ធ្វើការសិក្សាស្រាវជ្រាវពីសារប្រយោជន៍របស់វិស័យទេសចរណ៍ និងនិន្នាការវិវឌ្ឍទេសចរណ៍ថ្មីៗក្នុងតំបន់ និងអន្តរជាតិ
- ចូលរួមសហការជាមួយផ្នែកពាក់ព័ន្ធ ក្នុងការជំរុញកិច្ចអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពក្នុងវិស័យទេសចរណ៍
- ប្រមូលផ្តុំធនធានបញ្ញាញាណទេសចរណ៍ បទពិសោធន៍ ចំណេះដឹងទេសចរណ៍ ដើម្បីជំរុញការអភិវឌ្ឍវិស័យទេសចរណ៍
- សម្របសម្រួល តម្រង់ទិស សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ទាំងអស់នៅទូទាំងប្រទេសក្នុងការសិក្សាស្រាវជ្រាវទេសចរណ៍ឱ្យស្របតាមស្តង់ដា និងនិន្នាការអភិវឌ្ឍជាតិ តំបន់ និងអន្តរជាតិ
- រៀបចំគោលនយោបាយ គ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ យុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ឱ្យចំគោលដៅ និងមានប្រសិទ្ធភាព
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលអាចកើតមានក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់នាយកវិទ្យាស្ថានជាតិទេសចរណ៍។

**នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍** ដឹកនាំដោយប្រធាន មួយ(០១)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ មានការិយាល័យចំណុះចំនួន ០៤(បួន) ដូចខាងក្រោម៖

១-ការិយាល័យសិក្សាស្រាវជ្រាវវិភាគ និងគោលនយោបាយ យុទ្ធសាស្ត្រទេសចរណ៍

២-ការិយាល័យតាមដាន និងវាយតម្លៃការយល់ដឹងពីនិរន្តរភាពទេសចរណ៍
៣-ការិយាល័យទំនាក់ទំនងគ្រឹះស្ថានទេសចរណ៍ជាតិ និងអន្តរជាតិ
៤-ការិយាល័យបណ្តុះពុទ្ធិ និងពិសោធទេសចរណ៍។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យសិក្សាស្រាវជ្រាវវិភាគ និងគោលនយោបាយ យុទ្ធសាស្ត្រទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- សហការសិក្សា រៀបចំ ចងក្រង គោលនយោបាយ យុទ្ធសាស្ត្រទេសចរណ៍នានា
- សិក្សាស្រាវជ្រាវវិភាគអំពីឥទ្ធិពលនៃវិស័យទេសចរណ៍ លើវិស័យពាក់ព័ន្ធក្នុងសមត្ថកិច្ចពិគ្រោះយោបល់របស់ក្រសួងទេសចរណ៍ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍
- សិក្សា និងវិភាគអំពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា និងស្ថានភាពទេសចរណ៍ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់តំបន់ទេសចរណ៍ដែលមានសក្តានុពល ដើម្បីអភិវឌ្ឍឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- សិក្សាស្រាវជ្រាវ វិភាគពីផលប្រយោជន៍វិស័យទេសចរណ៍ ផលប៉ះពាល់វិជ្ជមាន អវិជ្ជមាននៃវិស័យនេះមកលើសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន
- សិក្សាស្រាវជ្រាវ វិភាគអំពីការទទួលរងនូវផលប៉ះពាល់ពីវិស័យដទៃមកលើវិស័យទេសចរណ៍
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រងការអភិវឌ្ឍទេសចរណ៍ និងផែនការជាតិសម្រាប់ការអភិវឌ្ឍទេសចរណ៍កម្ពុជា
- ព្យាករណ៍តម្រូវការហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ដទៃទៀតដែលបម្រើឱ្យវិស័យទេសចរណ៍។

**២-ការិយាល័យតាមដាន និងវាយតម្លៃការយល់ដឹងពីនិរន្តរភាពទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- ផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រងការអភិវឌ្ឍទេសចរណ៍ និងផែនការជាតិសម្រាប់ការអភិវឌ្ឍទេសចរណ៍កម្ពុជាឱ្យមាននិរន្តរភាព
- បោះពុម្ពផ្សាយរបកគំហើញនៃការសិក្សាស្រាវជ្រាវ
- ត្រួតពិនិត្យ គ្រប់គ្រងការបោះពុម្ពឯកសារសិក្សាស្រាវជ្រាវទេសចរណ៍នានា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការត្រួតពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ឱ្យចំគោលដៅ និងមានប្រសិទ្ធភាព
- សហការសិក្សាផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថានដែលអាចកើតមានក្នុងវិស័យទេសចរណ៍។

**៣-ការិយាល័យទំនាក់ទំនងគ្រឹះស្ថានទេសចរណ៍ជាតិ និងអន្តរជាតិ** មានតួនាទី និងភារកិច្ច៖

- សម្របសម្រួល តម្រង់ទិស សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ទាំងអស់នៅទូទាំងប្រទេសក្នុងការសិក្សាស្រាវជ្រាវទេសចរណ៍ឱ្យស្របតាមស្តង់ដា និងនិន្នាការអភិវឌ្ឍជាតិ តំបន់ និងអន្តរជាតិ
- សហការជាមួយគ្រឹះស្ថានទេសចរណ៍ជាតិ និងអន្តរជាតិ ធ្វើការសិក្សាស្រាវជ្រាវពីសារប្រយោជន៍របស់វិស័យទេសចរណ៍ និងនិន្នាការវិវឌ្ឍទេសចរណ៍ថ្មីៗក្នុងតំបន់ និងអន្តរជាតិ
- សហការជាមួយគ្រឹះស្ថានទេសចរណ៍អន្តរជាតិធ្វើការស្រាវជ្រាវ ប្រមូលធាតុចូល ដើម្បីរៀបចំគោលនយោបាយទេសចរណ៍តំបន់ចាំបាច់នានា។

**៤-ការិយាល័យបណ្ណាល័យ និងពិសោធទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំសមាគមគ្រឹះស្ថានអប់រំវិស័យទេសចរណ៍រដ្ឋ និងឯកជន
- រៀបចំសមាគម សាស្ត្រាចារ្យ គ្រូ និស្សិត សិស្ស និងអ្នកមានបទពិសោធន៍អំពីទេសចរណ៍
- សហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីកិច្ចសិក្សាស្រាវជ្រាវ
- ចងក្រងបណ្តាញអ្នកជំនាញទេសចរណ៍នានា
- រៀបចំកិច្ចប្រជុំពិភាក្សាតាមក្រុមជំនាញទេសចរណ៍នានា
- ប្រមូល ចងក្រង និក្ខេបបទស្រាវជ្រាវរបស់និស្សិតទេសចរណ៍ឆ្នើម
- ប្រមូល ចងក្រងបញ្ញាញាណទេសចរណ៍ បទពិសោធជោគជ័យលើការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍របស់បណ្តាប្រទេសលើពិភពលោក និងផ្សព្វផ្សាយ ដើម្បីជម្រុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យមាននិរន្តរភាព
- សហការជាមួយផ្នែកពាក់ព័ន្ធដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពក្នុងវិស័យទេសចរណ៍
- សហការជាមួយក្រុមជំនាញទេសចរណ៍ ដើម្បីធ្វើពិសោធលើសកម្មភាពទេសចរណ៍ចាំបាច់នានា។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ មានតួនាទី និងភារកិច្ចៈ

- រៀបចំគម្រោងផែនការសកម្មភាពការងារ និងចំណាយប្រចាំឆ្នាំរបស់ខ្លួនជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវ និងគោលនយោបាយទេសចរណ៍ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ